Rina

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*******

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី
លេខ ១២៥
ចុះថ្ងៃទី០៨ខែឧសភាឆ្នាំ១៩៩៨

សាលដីកា
លេខ : ១៨៦
ចុះថ្ងៃទី០២ខែកក្កដាឆ្នាំ១៩៩៨

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០២ ខែកក្កដា ឆ្នាំ១៩៩៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ខិត | មុន្នី | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២- | លោក | ម៉ែន | ស៊ុន | ចៅក្រមប្រឹក្សា |
| ៣- | លោក | យៀប | មួន | ចៅក្រមរបាយការណ៍ |
| ៤- | លោក | ស៊ិន | ខឹម | ចៅក្រមប្រឹក្សា |
| ៥- | លោក | ជីវ | កេង | ចៅក្រមប្រឹក្សា |
| ៦- | លោក | ឈឹម | ស៊ីផល | ចៅក្រមប្រឹក្សា |
| ៧- | លោក | សោម | សិរីវុឌ្ឍ | ចៅក្រមប្រឹក្សា |
| ៨- | លោក | ព្រាក់ | គីមសាន | ចៅក្រមប្រឹក្សា |
| ៩- | លោក | យស់ | សួឈឿន | ចៅក្រមប្រឹក្សា |

ក្រឡាបញ្ជី
កញ្ញា ភួង មន្ថា

តំណាងមហាអយ្យការ
លោក ម៉ែន សាឃឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណី ១៩៩ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ តាង ជុងមេង ភេទ ប្រុស អាយុ ៥៦ឆ្នាំ មុខរបរ ពាណិជ្ជករ មានទីលំនៅផ្ទះលេខ ១៨ ផ្លូវ ៥៧០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិឱ្យឈ្មោះ ជឹម វី ដែលមាន លោក ជា ឆេង ជាមេធាវី ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ប៊ុន ខាន់ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ៥២E0 ផ្លូវលេខ៩២ ក្រុមទី២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក

ក្រុងភ្នំពេញ ។ ដែលមាន លោក ឡាយ សំណាង ជាមេធាវី ។

<u>កម្មវត្ថុ</u> : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៦៩ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៧ របស់លោក ជា សេង ជាមេធាវី ថណាយក្តីឱ្យលោក ទាង ជុងចេង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១៩៩ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៥ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ លោកទាង ជុងចេង បានប្តឹងទាមទារដីឡូត៍លេខ៤៩ ,៥១ ,៥០ ,៥២ ផ្លូវលេខ៣៣៧ , ផ្លូវលេខ៣៣៩ ក្រុមទី៨៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ដោយសំអាងហេតុថា : ដីឡូត៍នេះ លោកបានទិញពីឈ្មោះ លឹម សោភ័ណ តាំងពីឆ្នាំ១៩៩២ ដោយបានសង់ផ្ទះឈើមួយនៅទីដី ហើយបានធ្វើលិខិតត្រឹមត្រូវតាមច្បាប់ ។ លុះដល់ថ្ងៃទី២៦_០២_៩៦ មានឈ្មោះប៊ុន ខាន់ មករុះរើវាយរបងរបស់ខ្លួនចេញ ហើយកំពុងសង់របងថ្មីទៀត ។

តាមពាក្យបណ្តឹងតប របស់ឈ្មោះ ប៊ុន ខាន់ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៩៦ លោក ប៊ុន ខាន់ ប្តឹងសុំឱ្យតុលាការលើកពាក្យបណ្តឹងរបស់លោក ទាង ជុងចេង ចោល ហើយសុំឱ្យតុលាការប្រគល់ដីឡូត៍លេខ ៥៣ ,៥៤ ,៥៥ ,៥៦ ផ្លូវលេខ៣៣៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក មកឱ្យលោក ដោយអាងហេតុថា : លោក ទាង ជុងចេង ជាជនបរទេស សញ្ជាតិចិនតៃវ៉ាន់ គ្មានគុណសម្បត្តិធ្វើជាម្ចាស់អចលនទ្រព្យនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានទេ ។ តាមមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញសាលក្រមលេខ១៣២ " ក " ចុះថ្ងៃទី ២៣_៨_៩៦ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៩_០២_៩៦ របស់ដើមចោទឈ្មោះ ទាង ជុងចេង ទុកជាត្រឹមត្រូវតាមទំរង់ តែលើកចោលដោយផ្ទុយនិងគតិច្បាប់ ។

២_ ទទួលលិខិតផ្ទេរចុះថ្ងៃទី ២២_៣_៩៦ របស់ដើមចោទឈ្មោះ ទាង ជុងចេង ផ្ទេរឱ្យឈ្មោះ ប៊ី ប៊ុនធុន និង លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១_៨_៩៦ របស់ឈ្មោះ ប៊ី ប៊ុនធុន ផ្ទេរឱ្យឈ្មោះ ចាល់ ចន្ទដារា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣_ សំរេចរឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច គឺពន្ធចុះបញ្ជី និងពន្ធហ្វឹង១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់សាក្សី ៣.០០០រៀល និងរង្វាន់អ្នកប្រគល់ដីកាកោះ ២.០០០រៀល សរុប ៧.០០០រៀល ។

៤_ ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី ២៧_៦_៩៦ របស់ឈ្មោះ ប៊ុន ខាន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៥_ ទទួលលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០១_៣_៩៦ របស់ឈ្មោះ ប៊ុន ខាន់ ផ្ទេរឱ្យឈ្មោះប៊ូ សាន់ន

ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៦_ បដិសេធលិខិតលេខ ២៣៩៥ ន.គ ចុះថ្ងៃទី ០៧_១១_៩២ របស់គណៈកម្មការក្រុងភ្នំពេញ ចោលជាអាសារបង់ដោយផ្ទុយ និងគតិច្បាប់ ។

៧_ ប្រគល់ដីឡូត៍លេខ ៩៣ ,៩៥ ,៩៤ ,៩៦ ផ្លូវលេខ ៣៣៧ , ៣៣៩ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឱ្យទៅឈ្មោះ ប៊ុន ខាន់ កាន់កាប់អាស្រ័យផល និង ចាត់ចែង ជាកម្មសិទ្ធិតទៅតាមលិខិតលេខ ៩៩០៣ ចុះថ្ងៃទី ២៦_១២_៩៥ របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ។

៨_ បង្គាប់ឱ្យឈ្មោះទាង ជុងទេង បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀលគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់សាក្សី ៣.០០០រៀល រង្វាន់អ្នកប្រគល់ដីការកោះ ២.០០០រៀល សរុប៧.០០០រៀល ប្រាក់នេះត្រូវបានកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេចកាលបើប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ ទាង ជុងទេង សងប្រាក់ ៧.០០០រៀលនេះទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ ១ភាគរយលើថ្លៃដីដែលត្រូវប្រគល់ ។

៩_ សាលាក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេលពីរខែគិតចាប់ពីថ្ងៃផុតកំណត់ប្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ទាង ជុងទេង ចុះថ្ងៃទី ០៧_១១_៩៦ ប្តឹងមិនសុខចិត្តត្រង់ចំនុចទី ៣_៦_៧ និងចំនុចទី ៨ នៃសេចក្តីសំរេច ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ៩០ ចុះថ្ងៃទី ២៤_០២_៩៧ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍ឈ្មោះ ទាង ជុងទេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែបដិសេធចោលដោយទាស់ និង គតិច្បាប់ ។

២_ ទទួលលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់ឈ្មោះ ប៊ុន ខាន់ ផ្ទេរឱ្យលោក ទី ពៅ មកដោះស្រាយនូវរឿងក្តីរបស់ខ្លួននៅសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣_ តំកល់សាលក្រមរដ្ឋប្បវេណីលេខ១៣២ " ក " ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៤_ រក្សាសិទ្ធិឱ្យឈ្មោះ ទាង ជុងទេង ដើម្បីប្តឹងទាមទារថ្លៃដីឈ្មោះ លឹម សោភ័ណ តាមច្បាប់ទៅតុលាការ ។

៥_ វិបរូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង ២៥០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៥០០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល សំរាប់អាជ្ញាធរតុលាការ ៥.០០០រៀល សរុប : ១៣០០០រៀល ។

៦_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈនាពេលសវនាការ ចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខ ទាង ជុងទេង សំរេចបើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះ ជា សេង " តំណាងឱ្យឈ្មោះទាង ផុងសេង " ចុះថ្ងៃទី ១១-៣-៩៧ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ២០៥ ចុះថ្ងៃទី ២៤-៤-៩៧ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងទាស់របស់លោក ជា សេង មេធាវីតំណាងក្តីឱ្យលោក ទាង ផុងសេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស និង គតិច្បាប់ ។

២- តំកល់សាលដីការដ្ឋប្បវេណីលេខ ៩០ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវី ដើមបណ្តឹងឧទ្ធរណ៍ និងចំពោះមុខលោក ទី ទៅ តំណាងឱ្យចុងបណ្តឹងឧទ្ធរណ៍ សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៩១ ចុះថ្ងៃទី ០៥-៥-៩៧ របស់លោកមេធាវី ជា សេង តំណាងក្តីឱ្យលោក ទាង ផុងសេង ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីកាលេខ ១៦៦ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលបណ្តឹងសាទុក្ខលេខ១៩១ ចុះថ្ងៃទី០៥-៥-៩៧ របស់លោកមេធាវីជា សេង តំណាងក្តីឱ្យលោក ទាង ផុងសេង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២០៥ ចុះថ្ងៃទី ២៤-៤-៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៧១ ចុះថ្ងៃទី ១០-៦-៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ទាង ផុងសេង បានបង់រួចហើយ គឺ ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វីងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវដកចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវឱ្យលោក ប៊ុន ខាន់ សងប្រាក់ចំនួន ១៩.០០០រៀលនេះទៅលោក ទាង ផុងសេង វិញ ។

៥- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៩៧ ។

បានឃើញសាលដីកាលេខ ១៩៩ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៣៩ ចុះថ្ងៃទី ១៧-១០-១៩៩៧ របស់សាលាឧទ្ធរណ៍

តាមអំណាចសាលដីការបស់តុលាការកំពូលលេខ ១៦៦ ចុះថ្ងៃទី១៨_៩_១៩៩៧ ។

២_ ប្រគល់ដីឡូត៍លេខ ៥៣ , ៥៥ ,៥៤ និង៥៦ ស្ថិតនៅផ្លូវលេខ ៣៣៧ , ៣៣៩ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ទៅឱ្យឈ្មោះ ប៊ុន ខាន់ គ្រប់គ្រងនិងកាន់កាប់ ជាកម្មសិទ្ធិតទៅ ។

៣_ បដិសេធលិខិតលេខ ២៣៥ នត.ចុះថ្ងៃទី១៧_១១_១៩៩២ របស់គណៈកម្មាធិការក្រុងភ្នំពេញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីឡូត៍ ចុះថ្ងៃទី ២២_១០_១៩៩២ ចោលជាអាសារបង់ ។

៤_ ទុកសិទ្ធិឱ្យឈ្មោះ ទាង ផុងទេង ប្ដឹងទាមទារថ្លៃដីឡូត៍ទំនាស់នេះពីឈ្មោះ លឹម សោភ័ណ ទៅតាមច្បាប់ ។

៥_ បង្គាប់ឱ្យឈ្មោះ ទាង ផុងទេង បង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃដីទំនាស់ ។

៦_ សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី ។ បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ៦៩ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ របស់លោកមេធាវី ជា សេង ថណាយក្ដីឱ្យលោក ទាង ផុងទេង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ទាង ផុងទេង ជាម្ចាស់បណ្ដឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ប៊ុន ខាន់ ជាចុងបណ្ដឹងសាទុក្ខ ។

បានស្ដាប់របាយការណ៍របស់ចៅក្រម

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

- បណ្ដឹងសាទុក្ខរបស់មេធាវីការពារឱ្យដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

- យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ បានសមស្របនឹងនីតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ជឹម រី " តំណាងឱ្យឈ្មោះ ទាង ផុងទេង " ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះថា : ខ្ញុំសូមប្ដឹងទាមទារយកដីនេះ ព្រោះថាដីនេះលោក ទាង ផុងទេង បានទិញដីនេះពីឈ្មោះ លឹម សោភ័ណ មានលិខិតលក់_ទិញ និង លិខិតផ្ទេរកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ។ ហើយបានធ្វើរោងចាំដីនេះជាប្រចាំរហូតមកដល់សព្វថ្ងៃនេះ ។ ចំពោះបញ្ហាសញ្ជាតិ វាជារឿងផ្សេងដោយឡែក វាគ្មានបញ្ហាទាក់ទងនិងការទិញ_លក់ដីនេះទេ ។ អាស្រ័យហេតុនេះ សូមលោកតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្ញុំផង ។

ក្រឡាបញ្ជីអានសារណាតបរបស់ឈ្មោះ ប៊ុន ខាន់ ជាចុងបណ្ដឹងសាទុក្ខ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោក ជា សេង ជាមេធាវីរបស់ដើមចោទ នៅពេលជំនុំជំរះ

ថា ៖ កូនក្តីរបស់ខ្ញុំឈ្មោះ ទាង ជុងចេង ពិតជាបានទិញដីពីឈ្មោះ លឹម សោភ័ណ ប្រាកដមែន ។ បាន ធ្វើបែបបទសុំរាក្យកាន់កាប់ត្រឹមត្រូវតាមច្បាប់ និងបង់ពន្ធ ៦% ជូនរដ្ឋ ។ កូនក្តីរបស់ខ្ញុំបានទទួលការកាន់កាប់ បណ្តោះអាសន្នតាមលិខិតលេខ ២៣៥៥ ភ.ត ចុះថ្ងៃទី ០៧_១១_៩២ ពីគណៈកម្មាធិការប្រជាជនក្រុងភ្នំពេញ។ ចំពោះបញ្ហាដីឡូត៍លេខ ៥៣ ,៥៤ ,៥៥ ,៥៦ របស់ឈ្មោះ ប៊ុន ខាន់ នោះគឺជាដីឡូត៍ ៤៩ ,៥០ ,៥១ ,៥២ របស់ឈ្មោះទាង ជុងចេង ទិញពីលោក លឹម សោភ័ណ ពិតមែន ។ ខ្ញុំសូមសំណូមពរឱ្យក្រុមប្រឹក្សាជំនុំជំរះ មេធ្លាតម្កល់សាលដីការបស់តុលាការកំពូលលេខ ១៦៦ ចុះថ្ងៃទី ១៨_៩_៩៧ ទុកជាត្រឹមត្រូវតាមច្បាប់ ។ សូម បដិសេធចោលសាលដីការបស់សាលាឧទ្ធរណ៍លេខ ២០៥ ចុះថ្ងៃទី ២៤_៤_៩៧ លើកទី១ និង សាលដីកាលេខ ១៤៩ ចុះថ្ងៃទី ០៦_៤_៩៨ លើកទី២ ចោលជាអាសារបង់ ។ បញ្ហាសញ្ជាតិមិនជាបញ្ហាទេ ព្រោះពេលនោះ រដ្ឋអំណាចបើទូលាយក្នុងការឱ្យជនបរទេសចូលមកវិនិយោគទុន ។ ចំពោះអត្តសញ្ញាណប័ណ្ណលេខ ៣៣២៣៦៧ ចុះ ថ្ងៃទី ០២_៧_៩២ និងលិខិតឆ្លងដែនលេខ ០០៦៦៥៥៦ ចុះថ្ងៃទី ៣១_៣_៩៨ ចុះហត្ថលេខាដោយ ឯកឧត្តម ហុក ឡុងឌី ទទួលស្គាល់ត្រឹមត្រូវ និង លិខិតបញ្ជាក់លេខ ២៥៦ ចុះថ្ងៃទី ៣១_៣_៩៨ បញ្ជាក់ថាលោក ទាង ជុងចេង មានសញ្ជាតិកម្ពុជា ។

ហេតុដូចនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេធ្លាពិនិត្យ និង សំរេចតាមច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡាយ សំណាង ជាមេធាវីរបស់ចុងចម្លើយនៅពេលជំនុំជំរះ ថា ៖ ឈ្មោះ ប៊ុន ខាន់ ពិតជាបានទិញដីឡូត៍លេខ ៥៣ ,៥៤ ,៥៥ ,៥៦ ចុះថ្ងៃទី០៧_០២_៩៥ ដែលមាន លិខិតបញ្ជាក់ពីសង្កាត់ ខណ្ឌ និង សាលាក្រុងភ្នំពេញ ។ ម៉្យាងទៀតឈ្មោះ ទាង ជុងចេង ពីតជាបានទិញ ដីពីឈ្មោះ លឹម សោភ័ណ មែន ប៉ុន្តែឈ្មោះនេះ ជាជនជាតិចិនតៃវ៉ាន់ មិនអាចទិញដីដោយខ្លួនផ្ទាល់ខ្លួនទេ យោងតាមអនុក្រឹត្យលេខ ២៥អនក្រ. និង របាយការណ៍ ចុះថ្ងៃទី ១២_៩_៩៧ មានបញ្ជាក់ស្រាប់ ។ តាម របាយការណ៍របស់ស៊ើបអង្កេត មានបញ្ជាក់ក្នុងរឿងសំណុំរឿងស្រាប់ និង តាមមាត្រា ៧៦ ច្បាប់ភូមិបាលហើយ មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ក៏បានបញ្ជាក់ដែរ ។ ម៉្យាងវិញទៀតច្បាប់រដ្ឋធម្មនុញ្ញបានហាមឃាត់ និង មាត្រា១៦ ច្បាប់វិនិយោគទុន និង អនុក្រឹត្យលេខ ២៥ ត្រង់មាត្រា ២ ។ ចំពោះលិខិតធ្វើវិនិយោគទុន ដែលចុះបញ្ជីនៅ ក្រសួងពាណិជ្ជកម្មរបស់លោក ទាង ជុងចេង ក៏គ្មានដែរ ។ បញ្ហាសញ្ជាតិនេះលោក ទាង ជុងចេង បាន ធ្វើលិខិតក្លែងសញ្ជាតិ និង លិខិតឆ្លងដែនខុសច្បាប់ ត្រូវបានអគ្គនាយកនគរបាលជាតិ ឱ្យចាប់ខ្លួន ទាង ជុងចេង តាមដីកាឃាត់ខ្លួនរបស់អគ្គព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ ។

ខ្ញុំសំណូមពរ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះមេធ្លាសំរេចតម្កល់សាលក្រមរបស់តុលាការក្រុងភ្នំពេញ និង សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសារ អ្នកស្រី ជឹម វី និង សារណារបស់លោក ប៊ុន ខាន់ និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ៦៩ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ របស់លោក ជា សេង មេធាវីរបស់លោក ទាង ជុងមេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការក្រុងភ្នំពេញដែរ ដែលសំរេចបដិសេធលិខិតលេខ ២៣៤៥ ន.ត ចុះថ្ងៃទី០៧_១១_៩២ របស់គណៈកម្មាធិការក្រុងភ្នំពេញចោលជាអសារបង់ ហើយសំរេចប្រគល់ដីឡូត៍លេខ ៥៣_៥៤_៥៥_៥៦ ផ្លូវលេខ៣៣៧ និង៣៣៩ សង្កាត់បឹងកក់២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ឱ្យទៅលោក ប៊ុន ខាន់ កាន់កាប់អាស្រ័យផល និង ចាត់ទុកជាកម្មសិទ្ធិ ដោយអាងហេតុថា លិខិតផ្ទេរសិទ្ធិដីឡូត៍លេខ ៤៩_៥១ និង ៥០_៥២ ពីឈ្មោះ លឹម សោភ័ណ ទៅឈ្មោះ ទាង ជុងមេង និងលិខិតលេខ ២៣៤៥ អធ.ចុះថ្ងៃទី០៧_១១_៩២ របស់គណៈកម្មាធិការក្រុងភ្នំពេញ ធ្វើឡើងផ្ទុយនិងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៦ នៃច្បាប់វិនិយោគទុនកម្ពុជា ពីព្រោះលោក ទាង ជុងមេង ពុំមានសញ្ជាតិជាខ្មែរនោះ ជាការភាន់ច្រឡំពីព្រោះថា លិខិតទាំងពីរខាងលើនេះបានធ្វើឡើងមុនការចូលជាធរមាន នៃរដ្ឋ_ធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ( ២១_៩_៩៣ ) នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ( ០៤_៨_៩៤ ) និងនៃច្បាប់ស្តីពីសញ្ជាតិ ( ២០_៨_៩៦ ) ហើយច្បាប់ទាំងបីខាងលើនេះពុំមានអនុភាពអាក់ថយឡើយ ។ ហើយម្យ៉ាងទៀតលិខិតលេខ ២៣៤៥ ន.ត ចុះថ្ងៃទី ០៧_១១_៩២ របស់គណៈកម្មាធិការក្រុងភ្នំពេញ គ្រាន់តែអនុញ្ញាតិឱ្យ លោក ទាង ជុងមេង កាន់កាប់ដីនេះជាបណ្តោះអាសន្នតែប៉ុណ្ណោះ ពុំមែនអនុញ្ញាតិឱ្យជាកម្មសិទ្ធិទេ ។

- យល់ឃើញថា លិខិតផ្ទេរសិទ្ធិដីឡូត៍លេខ ៤៩_៥១_៥០ និង៥២ ឬដីឡូត៍លេខ ៥៣_៥៤_៥៥_៥៦ ចុះថ្ងៃទី ២២_១០_៩២ ពីលោក លឹម សោភ័ណ មកលោក ទាង ជុងមេង ដែលធ្វើឡើងដោយប្រធានក្រុមទី៨៤ អនុប្រធានសង្កាត់បឹងកក់ ២ , សមាជិកអចិន្ត្រៃយ៍ខ័ណ្ឌទួលគោក ចុះហត្ថលេខា និងមានការអនុញ្ញាតិឱ្យកាន់កាប់ជាបណ្តោះអាសន្នពីគណៈកម្មាធិការក្រុងភ្នំពេញទៀតផងនោះ ធ្វើឡើងតាមរូបភាពជាការទិញលក់ ពីអ្នកទិញបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យអ្នកលក់ ហើយអ្នកលក់បានប្រគល់ដីឱ្យអ្នកទិញកាន់កាប់រួចហើយ ។ ទាំងអ្នកលក់ ទាំងអ្នកទិញ ពុំបានប្តឹងតវ៉ាអ្វីឡើយ ហើយអ្នកទិញក៏បានចុះបញ្ជីបង់ពន្ធប្រថាប់ត្រារួចត្រឹមត្រូវតាមមាត្រា៩១ នៃក្រិត្យ.ច្បាប់លេខ ៣៨ ក្រ.ច និងមាត្រា ១៨២ នៃច្បាប់ភូមិបាលហើយ ដូច្នេះលោក លឹម សោភ័ណ អស់សិទ្ធិជាម្ចាស់លើដីនេះទៀតហើយ ។

- យល់ឃើញថា លិខិតផ្ទេរសិទ្ធិកាន់កាប់ដីឡូត៍លេខ ៥៣_៥៤_៥៥ និង៥៦ ចុះថ្ងៃទី០៧_០២_៩៥ ពីលោក លឹម សោភ័ណ ដែលអស់សិទ្ធិជាម្ចាស់ដីហើយនោះ ទៅឱ្យលោក ប៊ុន ខាន់ តាមរូបភាពនៃការកាត់បំណុលនោះ ត្រូវទុកជាមោឃៈតាមមាត្រា ៣៥ និង ៧១ នៃក្រិត្យ.ច្បាប់លេខ ៣៨ ក្រ.ច ( លក់របស់អ្នកដទៃ ) និងមាត្រា ១៥២ នៃច្បាប់ភូមិបាល ដូច្នេះរាល់លិខិតស្នាម និងបុព្វសិទ្ធិ ឬកាតព្វកិច្ច ដែលកើតចេញពីលិខិតនេះត្រូវទុកជាមោឃៈ ។

- យល់ឃើញថា ដោយបណ្តាសញ្ញាតិរបស់លោក ចាង ជុងចេង ពុំទាន់ឡាស់លាស់នៅឡើយនោះ តុលាការកំពូលគប្បីពិចារណាអំពីសិទ្ធិរបស់លោកលើដីកើតហេតុនេះ ។

- យល់ឃើញថា លោក ប៊ុន ខាន់ បានធ្វើសារណាការពាររឿងក្តីរបស់លោកមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងពីបណ្តាសញ្ញាតិរបស់លោក ចាង ជុងចេង មកសំអាង ដើម្បីលុបការទិញលក់ដីរបស់លោក លឹម សោភ័ណ និងលោក ចាង ជុងចេង នោះ តុលាការកំពូលពុំអាចលើកយកមកពិចារណាឡើយ ពីព្រោះការលក់ទិញនេះ ធ្វើឡើងមុនការចូលជាធរមាននៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីសញ្ញាតិ ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងថា លោកចាង ជុងចេង បានបោះបង់ចោលដីនេះហួសពី ៣ឆ្នាំនោះគឺជាការភាន់ច្រឡំ ពីព្រោះមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លោកចាង ជុងចេង បានសង់ផ្ទះលើដីនេះ ហើយដាក់កម្មករឱ្យនៅចាំជាប្រចាំទៀតផង ។

- យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ ១៤៩ ចុះថ្ងៃទី ០៦_៤_៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខ អ្នកស្រី ជឹម វី តំណាងលោក ចាង ជុងចេង កំបាំងមុខលោក ប៊ុន ខាន់ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១_ ទទួលបណ្តឹងសាទុក្ខលេខ ៦៩ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ១៩៩៨ របស់លោក ជា ឆេង មេធាវីរបស់លោក ចាង ជុងចេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីកាវិនិច្ឆ័យលេខ ១៤៩ ចុះថ្ងៃទី ០៦_៤_៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ ប្រគល់ដីឡូត៍លេខ ៤៩_៥១_៥០ និង ៥២ គឺដីឡូត៍លេខ ៥៣_៥៥_៥៤ និង៥៦ថ្មី ផ្លូវលេខ

៣៣៧ និងលេខ៣៣៩ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ តាមចំនួនប្លង់ចុះថ្ងៃទី០៣-១១-៩២ របស់ការិយាល័យសុរិយោដីក្រុងភ្នំពេញ ឱ្យទៅលោកទាង ជុងទេង គ្រប់គ្រងជាបណ្តោះអាសន្ន ហើយឱ្យលោកទាង ជុងទេង ទំនាក់ទំនងជាមួយអាជ្ញាធរ មានសមត្ថកិច្ច ដើម្បីចាត់ចែងដីនេះតាមការកំណត់នៃច្បាប់ ។

៤- ទុកជាមោឃៈលិខិតលេខ ៤៩០៣ ន.ត.ស ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៥ របស់ប្រតិភូ-រាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ទាំងមូល ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោកទាង ជុងទេង បានបង់រួចហើយគឺ៖

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។
- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតម្រូវឱ្យលោក ប៊ុន ខាន់ សងប្រាក់ចំនួន ១៩.០០០រៀលនេះ ទៅលោក ទាង ជុងទេង វិញ ។

បង្គាប់ឱ្យលោកប៊ុន ខាន់ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដី១២០.០០០ដុល្លារអាមេរិក។

៦- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០២ ខែកក្កដា ឆ្នាំ១៩៩៨ ។